# រឿង មហាចោរនៅទល់ដែន

### ភាគទី៣

- ស្រីដែលមានរូបល្អ ដូចអូន មិនគួរមានចិត្តអាក្រក់សោះ។

ថាហើយកាមាសើចក្អាកក្អាយ សើចពុះរំពង។

- យី! អីលោកហ៊ានហៅរូបខ្ញុំអូនផង? ខ្ញុំជាប្អូនលោកពីកាលណាមក? មនុស្សអីក៏មានចិត្តឫស្សា មុខក្រាស់ម្ល៉េះ? ថាហើយ នាងច្រត់ដៃនឹងចង្កេះនាង សម្លឹងមុខបុរសគ្មានប្រហែលឡើយ។កាមាសើចដដែល។

- បើមិនឲ្យហៅអូន តើឲ្យខ្ញុំហៅអីវិញ? ហៅបង? ហៅអ្នកបង? ហៅមិនកើតទេ។

នាងទេវីពួសម្តីចុងក្រោយនេះ នាងស្មានក្នុងចិត្តថា ប្រហែលបុរសនេះឃើញនាង និងមានន្ទហើយ ពីព្រោះកាមាត្រូវជាប្អូនបង្កើតរបស់មានន្ទ។ នាងខំទប់សេចក្តីអៀនខ្មាស ប្រឹងធ្វើទឹកមុខដដែល។

- យី! ចំណាស់ប៉ុនខ្ញុំ លោកហៅខ្ញុំបងមិនបានឬ?
- ហៅមិនបាន ព្រោះខ្ញុំស្រឡាញ់អ្នកយូរមកហើយ។ខ្ញុំចង់បានអ្នកជាប្រពន្ធខ្ញុំ។ខ្ញុំប្រាថ្នាលើកតម្កើងអ្នកឲ្យខ្ពស់ផុតអស់នារីដែលមាននៅលើលោកនេះ។ ខ្ញុំចង់ឲ្យអ្នកថ្កុំថ្កើងដោយសារស្នាដៃខ្ញុំ។
- មិនបាច់និយាយច្រើនទេ! ខ្ញុំមិនត្រូវការឲ្យលោកលើកតម្កើងខ្ញុំទេ ពាក្យថោក គំនិតទាបខ្ញុំមិនចង់ស្តាប់លោកទេ។

បុរសឡើងក្រហមស្ទឹកត្រចៀក។ដោយស្រឡាញ់នាងទេវីពេក កាមាមើលមុខនាងឃើញល្អអ្វី ក៏ល្អម្ល៉េះទេ ទោះកំពុងខឹងក្រញូវដូច្នោះក៏នៅតែល្អ។សម្លេងពីរោះអ្វីក៏ពីរោះម្ល៉េះ ទោះគំហក ជៀលត្មះប៉ុណ្ណោះហើយ ក៏នៅតែពីរោះ។អ្នកមើលមុខនាងដោយអង្វរ ហើយពោលថា៖

អត្ថបទដោយ៖ មាស សុភាព

- ខ្ញុំទាប អ្នកខ្ពស់ បានជាខ្ញុំស្រឡាញ់អ្នក។ខ្ញុំសូមចិត្តអ្នកចុះ កុំខឹងអ្វីនឹងខ្ញុំ។ ដោយស្រឡាញ់អ្នកពេកហើយ បានជាអម្បាញ់មិញ ខ្ញុំស្ទុះមកឱបអ្នក។សូមទោសអ្នកចុះ កុំប្រកាន់ខ្ញុំ។ ខ្ញុំពិតជាស្រឡាញ់អ្នកមែន។ ថ្ងៃនេះខ្ញុំចង់និយាយជាមួយនឹងអ្នកឲ្យបានវែងឆ្ងាយ ដើម្បីអ្នកយល់...។
- ខ្ញុំមិនបាច់ស្តាប់លោកទេ។ ខ្ញុំមិនចង់ស្តាប់ ខ្ញុំមិនចង់យល់លោកទេ។

កាមាខឹងធ្លលក្នុងចិត្ត ដោយមើលឃើញជាក់ថា ធម៌ត្រជាក់មិនបានការ។ អ្នកខាំធ្មេញដើរចូលទៅរកនាង ប្រាថ្នាគិតចាប់គំហែង ចាប់ដោយកម្លាំងតែម្តង។ នារីសម្លឹងបុរសយ៉ាងកាចបំផុត។ កាមាទុចង៉ក់។ នាងពោលថា៖

- កាមា! កាមា! កាមា! កុំចូលជិត! តែបើចូល មានតែស្លាប់ និងរស់ប៉ុណ្ណោះ!
- ខ្ញុំមិនថយមួយជំហានទេ។
- ឈប់! កាមា បើចង់និយាយនឹងយើងណាស់ ឈរឲ្យស្មៀមមួយកន្លែងចម្ងាយបីម៉ែតពីយើង។អើ! ឆ្លើយ៉ាងហ្នឹង បានហៅថ្ងៃថ្នូរ ពេញដោយជាកូនប្រុស។ ឥឡូវនិយាយមកចុះ បើពេញជាកូនប្រុសព្រះកម្ពុតមែន ខ្ញុំស្តាប់។
- អ្នកជ្រាបទេ? ខ្ញុំស្រឡាញ់អ្នកយូរមកហើយ។ឪពុកខ្ញុំ ព្រះកម្ពុតជាចៅហ្វាយលើកពផែនដី ចង្វាត់សិរីសោភ័ណនេះ។ ខ្ញុំអាចសូមឪពុកខ្ញុំ ចូលដណ្តឹងអ្នកបាន។តែខ្ញុំគ្រាន់តែចង់ដឹងចិត្តអ្នកបន្ថែមបន្តិចទៀតទេ បានជាខ្ញុំតែងឆ្លៀតឱកាស ចង់ជួបនឹងអ្នក ដើម្បីយើងនិយាយគ្នាឲ្យដឹងដើម ដឹងចុងបន្តិច។ឪពុកខ្ញុំប្រាកដជាស្រឡាញ់អ្នកដែរ ពីព្រោះគាត់បាននិយាយដំណាលពីរឿងអ្នករឿយៗណាស់។
- ឪពុកលោកតំណាលពីគ្រប់ស្រីដែលមានរូបល្អ។នេះជាការធម្មតាទេ។
- ទេ! លោកប្រហែលជាចង់បានអ្នកជាកូនប្រសាដែរ។
- ប្រហែលជាចង់បានខ្ញុំយកទៅធ្វើជាប្រពន្ធខ្លួនឯងទេដឹង? ឪពុកលោកជាមនុស្សមកពីអវចី ប្រពន្ធរាប់ដប់ម្ភៃ លួចកូនគេ លួចប្រពន្ធគេ។
- យីអ្នក! ខ្ញុំនិយាយមិនស្តាប់ បានតែបងមានន្ទប្ញ ទើបនិយាយស្តាប់បាន?

អត្ថបទដោយ៖ មាស សុភាព

- អើ! ខ្ញុំស្តាប់តែមាននូពិតប្រាកដមែនៗមាននូជាគូសង្សារខ្ញុំ ជាប្តីខ្ញុំពេញចិត្តៗ អើ! អើ! បើកាមាឯងជាប្អូនមាននូ ហើយដឹងថាមាននូជាបងកាមាឯងស្រឡាញ់ខ្ញុំហើយ ម្តេចក៏កាមាឯងមកស្រឡាញ់ខ្ញុំទៀត?ឬចង់ក្បត់មាននូជាបងបង្កើត? លោកក្បត់ចុះ តែខ្ញុំ ខ្ញុំមិនក្បត់ទេៗកាមា! ខ្ញុំសូមលោករកស្រីណាទៀតទៅ មិនខ្វះទេ ស្រីល្អនោះៗតែធ្វើដូច្នោះ នាំឲ្យបាក់បែកគ្រួសារយើងទេៗទៅ! កាមាអញ្ជើញទៅចុះៗ

កាមារឹតតែខឹងទៀត អ្នកសំឡក់នាងទេវីស្ទើរធ្លុះពីរបីៗខ្យលគំនុំមួយ បោកមកលើដួងចិត្តអ្នកដូចព្យុះសង្ឃរាៗយ៉ាងរហ័សអ្នកបែរមុខចេញ ស្ទុះលោតកាត់គុម្ពផ្កាមួយ ពីមួយទៅមួយ តម្រង់ទៅគេហដ្ឋានព្រះកម្ពុតឪពុកៗ

នាងកញ្ញាទេវីបានធូរ ដូចដកបន្ទាពីដើមទ្រូង ធូរចិត្ត ឈរមើលកាមាដែលបាត់ទៅៗ អស់កម្លាំងហេវ នារីដើរមួយៗទៅកាន់ផ្ទះនាង៕

(សូមរង់ចាំតាមដានភាគទី៣ នៅសប្តាហ៍ក្រោយ)

អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ មាស សុភាព